# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

អ្នកនាំពាក្យ គ.ជ.ប

លេខ : ០៧៦ គ.ជ.ប

ថ្ងៃព្រហស្បតិ៍ ១០រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ២០២៣

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ប្រធាន គ.ជ.ប ទទួលជួបអ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

ឆ្លើយតបតាមសំណើរបស់អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៧ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១១:០០ **ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានទទួលជួប លោក **វិទិត មុនតាប៊ន**( Mr.Vitit Muntarbhorn) អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា រួមជាមួយសហការីមន្ត្រីផ្នែកសិទ្ធិមនុស្សមួយចំនួនទៀត នៅទីស្តីការសាលប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីពិភាក្សាអំពីការងារបោះឆ្នោតនៅកម្ពុជា។

ជាដំបូង **ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានសម្តែងការស្វាគមន៍ចំពោះ លោក **វិទិត មុនតាប៊ន** ដែលបានអញ្ជើញមកពិភាក្សាការងារជាមួយ គ.ជ.ប នាឱកាសនេះ។ ឯកឧត្តមក៏បានរម្លឹកអំពីជំនួបលើកទីមួយជាមួយលោក ក្នុងអំឡុងខែសីហា ឆ្នាំ២០២២ ម្តងរួចមកហើយ នៅពេលនេះ គ.ជ.ប បានត្រៀមលក្ខណៈដើម្បីពិភាក្សាការងារជាមួយគ្នាជាបន្តទៀត។

ជាកិច្ចបន្ត **លោក វិទិត មុនតាប៊ន** បានថ្លែងអំណរគុណដល់ **ឯកឧត្តម ប្រាជ្ញ ចន្ទ** ដែលទទួលជួបពិភាក្សាការងារ។ លោកបន្តថា នេះជាបេសកកម្មលើកទីមួយ ក្នុងឆ្នាំ២០២៣ ដើម្បីប្រមូលព័ត៌មានធ្វើរបាយការណ៍ដាក់ជូនអង្គការសហប្រជាជាតិ។ បេសកកម្មលើកនេះលោកនឹងមិនធ្វើសន្និសីទសារព័ត៌មាន ឬក៏ធ្វើសេចក្តីប្រកាសព័ត៌មានទេ។ លោកបន្តទៀតថា អាណត្តិរបស់អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្ស គឺតាមដានការងារសិទ្ធិមនុស្សនៅក្នុងប្រទេស បន្ទាប់មករាយការណ៍ទៅអង្គការសហប្រជាជាតិ។ ក្នុងជំនួបនៅពេលនេះ លោកចង់ដឹងអំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នាពេលកន្លងមក ការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត។ មួយទៀត លោកក៏ចង់បានព័ត៌មានអំពីការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅឆ្នាំ២០២៥ ផងដែរ រួមទាំងបញ្ហាប្រឈមនានា ដែល គ.ជ.ប បានជួបប្រទះក្នុងការបោះឆ្នោត។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh

ក្នុងការឆ្លើយតបទៅនឹងសំណួរខាងលើ **ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានជម្រាបជូនថា គ.ជ.ប គឺជាអង្គការរៀបចំការបោះឆ្នោតដែលមានសមត្ថកិច្ចរៀបចំ ចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមការកំណត់នៃច្បាប់ និងត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួនប្រកបដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិតេយ្យ សេរីពហុបក្ស។ ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ គ.ជ.ប បានដាក់ចេញនូវបទបញ្ជា និងនីតិវិធី រៀបចំប្រតិទិនបោះឆ្នោត និងផែនការមេ ដើម្បីឱ្យការងារបោះឆ្នោតនឹងប្រព្រឹត្តទៅតាមដំណាក់កាល និងពេលវេលាដែលបានកំណត់។ ឯកឧត្តមប្រធានបានបញ្ជាក់ជូនអំពីដំណាក់កាលសំខាន់ទាំងបួន នៃដំណើរការរៀបចំការបោះឆ្នោត។ ឯកឧត្តមប្រធានបន្តថា ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២២ គឺជាដំណាក់កាលដំបូងនៃដំណើរការបោះឆ្នោតដែលត្រូវបានប្រព្រឹត្តទៅរយៈពេល ៥០ថ្ងៃ នៅគ្រប់ឃុំ សង្កាត់ ទូទាំងប្រទេស។ លទ្ធផលផ្លូវការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២២ អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុប ចំនួន ៩,៧១០,៦៥៥ នាក់ស្មើនឹង ៨៩.២៨% ស្ត្រីចំនួន ៥,១៦១,៦០៩នាក់ និងមានការិយាល័យបោះឆ្នោតសរុប ២៣,៧៨៩ការិយាល័យ។ ចំពោះបញ្ជីបោះឆ្នោតផ្លូវការ ត្រូវបានអង្គការខុមហ្វ្រែលបានធ្វើសវនកម្ម និងវាយតម្លៃថា បញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២១ មានភាពពេញលេញ ៩៨.៦៩% ហើយបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ គឺអាចទទួលយកបាន។

អំពីដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ **ឯកឧត្តម ប្រាជ្ញ ចន្ទ** បានជម្រាបជូនអំពីចំនួនគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីឈរឈ្មោះ មាន ២០ គណបក្ស ហើយត្រូវបាន គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ បដិសេធការចុះបញ្ជីចំនួន ២ គណបក្សនយោបាយ ដោយគណបក្សទាំងពីរនោះមិនបានបំពេញឯកសារត្រឹមត្រូវតាមច្បាប់កំណត់។ សរុបជារួម មាន ១៨ គណបក្សនយោបាយ ត្រូវបានទទួលស្គាល់ជាផ្លូវការក្នុងការចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

អំពីដំណាក់កាលឃោសនាបោះឆ្នោត **ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានជម្រាបជូនអំពីសកម្មភាពរបស់គណបក្សនយោបាយ អាចឃោសនាបានច្រើនរូបភាពតាមការកំណត់ក្នុងបទបញ្ជា និងនីតិវិធី របស់ គ.ជ.ប។ ការឃោសនាបោះឆ្នោតត្រូវបានប្រព្រឹត្តទៅរយៈពេល ២១ថ្ងៃ ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតទាំងអស់ត្រូវបញ្ចប់ត្រឹម២៤ម៉ោងមុនថ្ងៃបោះឆ្នោត។ ក្នុងរយៈពេល ២១ថ្ងៃនេះ គណបក្សនយោបាយនីមួយៗបានធ្វើសកម្មភាពឃោសនារកសំឡេងឆ្នោតតាមមធ្យោបាយ និងលទ្ធភាពរៀងៗខ្លួន ក្រោមរូបភាពដូចជាការហែក្បួនឃោសនា ការជួបប្រជុំជាមួយសមាជិកគណបក្ស សកម្មជន និងអ្នកគាំទ្រ ការចាក់មេក្រូផ្សព្វផ្សាយតាមទីស្នាក់ការគណបក្ស និងមេក្រូចល័តតាមភូមិ ការចែកខិត្តប័ណ្ណ និងសកម្មភាពផ្សព្វផ្សាយគោលនយោបាយរបស់ខ្លួនផ្សេងៗទៀត។ ជាមួយគ្នានេះ គ.ជ.ប បានរៀបចំ



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh

កម្មវិធីស្មើភាពជូនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដើម្បីផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋដោយឥតគិតថ្លៃ។

ចំពោះដំណាក់កាលបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត **ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានមានប្រសាសន៍ថា ការបោះឆ្នោតត្រូវបានប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ចាប់ពីវេលាម៉ោង ៧:០០នាទីព្រឹក រហូតដល់ម៉ោង ៣:០០នាទីរសៀល តាមការិយាល័យបោះឆ្នោតទាំង ២៣,៧៨៩ការិយាល័យ ទូទាំងប្រទេស។ អ្នកដែលបានទៅបោះឆ្នោតសរុបចំនួន ៨,២១៤,៤៣០នាក់ ស្មើនឹង ៨៤.៥៩% នៃចំនួនអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ៩,៧១០,៦៥៥នាក់។ សន្លឹកឆ្នោតបានការសរុបចំនួន ៧,៧៧៤,២៧៦សន្លឹក និងសន្លឹកឆ្នោតមិនបានការសរុបចំនួន ៤៤០,១៥៥សន្លឹក។ គណបក្សនយោបាយដែលទទួលបានអាសនៈ មានចំនួន ២ គណបក្ស គណបក្សប្រជាជនកម្ពុជា មានសំឡេងគាំទ្រ ៦,៣៩៨,៣១១សំឡេង ទទួលបាន ១២០អាសនៈ។ គណបក្សហ៊្វុនស៊ិនប៉ិច មានសំឡេងគាំទ្រ ៧១៦,៤៩០សំឡេង ទទួលបាន ៥អាសនៈ។ ឯកឧត្តមប្រធានបានបញ្ជាក់បន្ថែមថា ការបោះឆ្នោតនាពេលកន្លងមកមានការចូលរួមសង្កេតមើលពីអ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិជាច្រើនម៉ឺននាក់ ក្នុងនោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិប្រមាណ ៦០០នាក់ មកពី ៦០ ស្ថាប័នអន្តរជាតិ និងអង្គការនានា។ ទន្ទឹមនឹងនោះ គណបក្សនយោបាយបានដាក់ភ្នាក់ងារគណបក្សរបស់ខ្លួនក្នុងការតាមដានមើលដំណើរការបោះឆ្នោត ដើម្បីប្តឹងតវ៉ា និងប្តឹងជំទាស់ក្នុងករណីណាមួយ។ ឯកឧត្តមប្រធានបានបន្តទៀតថា អ្នកសង្កេតការណ៍អន្តរជាតិបានវាយតម្លៃថា ការបោះឆ្នោតបានប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព ឯករាជ្យ មានវិជ្ជាជីវៈ និងតម្លាភាព។ រីឯការរាប់សន្លឹកឆ្នោតដោយដៃមានលំដាប់លំដោយ ហើយការបញ្ជូនលទ្ធផលនៃការបោះឆ្នោតតាមលំដាប់ថ្នាក់មក គ.ជ.ប តាមប្រព័ន្ធអេឡិចត្រូនិក បញ្ជាក់ពីតម្លាភាពយ៉ាងខ្លាំងគួរឱ្យទុកចិត្តបាន។

ពាក់ព័ន្ធនឹងការបោះឆ្នោតនៅឆ្នាំ២០២៤ **ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានជម្រាបជូនថា ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤។ សមាជិកព្រឹទ្ធសភាមានចំនួន ៦២រូប ក្នុងនោះ ២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប និង ៥៨រូបទៀត ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ មណ្ឌលបោះឆ្នោតត្រូវរៀបចំ និងបែងចែកជា ៨ ភូមិភាគ។ អ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែងនៅក្នុងក្របខណ្ឌនៃភូមិភាគនីមួយៗមានចំនួនសរុប ១១,៧៤៧ នាក់ ការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតនេះមានចំនួន ៣៣ ការិយាល័យ។

**ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានបន្តថា ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ចាប់ផ្តើមពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៣ និងត្រូវបញ្ចប់នៅ



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh

ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ ពោលគឺមានរយៈពេល ១៥ថ្ងៃ។ គ.ជ.ប បានសម្រេចទទួលស្គាល់ជាផ្លូវការលើពាក្យសុំចុះបញ្ជីរបស់ **គណបក្សប្រជាជនកម្ពុជា** និង គ.ជ.ប កំពុងពិនិត្យលើពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់ **គណបក្ស ឆន្ទៈខ្មែរ** និង **គណបក្ស កម្លាំងជាតិ** ។

**ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប ក៏បានជម្រាបជូន ប្រតិភូអំពីការឃោសនាបោះឆ្នោតគឺត្រូវធ្វើឡើងនៅតាមមណ្ឌលភូមិភាគនីមួយៗ ហើយយុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល ១៤ថ្ងៃ ចាប់ពីថ្ងៃទី១០ ដល់ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤។

ចំពោះការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា **ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប ជម្រាបជូនថា នឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤ ដោយចាប់ផ្តើមពីម៉ោង ៧:០០ នាទីព្រឹក ដល់ម៉ោង ១៥:០០ នាទីរសៀល។ បន្ទាប់ពីបញ្ចប់ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត នឹងត្រូវបានអនុវត្តភ្លាមៗនៅទីតាំងតែមួយ ដោយការិយាល័យបោះឆ្នោត នឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត។ គ.ជ.ប នឹងប្រកាសផ្សាយលទ្ធផលបឋមនៃការបោះឆ្នោត ដោយផ្អែកលើទិន្នន័យលទ្ធផលនៃការរាប់សន្លឹកឆ្នោតតាមការិយាល័យដែល គជ.ខប បានបញ្ចូល និងបញ្ជូនមក គ.ជ.ប តាមប្រព័ន្ធអ៊ីនធឺណិត។ លទ្ធផលនៃការបោះឆ្នោតគ្រប់ការិយាល័យបោះឆ្នោតទូទាំងប្រទេស ក៏មានបង្ហោះផ្សាយជាសាធារណៈនៅលើគេហទំព័រផ្លូវការរបស់ គ.ជ.ប។ គ.ជ.ប នឹងផ្សាយលទ្ធផលនៃការបោះឆ្នោតផ្លូវការយ៉ាងយូរនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ ឬមុនកាលបរិច្ឆេទនេះ តាមករណីមាន ឬគ្មានពាក្យបណ្តឹង ឬគ្មានការបោះឆ្នោតសាជាថ្មី។

ពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ **ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានមានប្រសាសន៍ថា គ.ជ.ប បានត្រៀមលក្ខណៈរួចរាល់ហើយ ក្នុងនោះសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវបាន គ.ជ.ប ពិនិត្យរួចរាល់ហើយ បន្ទាប់មកត្រូវបញ្ជូនទៅឱ្យភាគីពាក់ព័ន្ធផ្តល់អនុសាសន៍។

ជាកិច្ចបន្តទៀត **លោក ទិទិត មុនតាប៊ែន** បានដាក់សំណួរជាបន្តបន្ទាប់ពាក់ព័ន្ធនឹងការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ និងអំពីឯករាជ្យអព្យាក្រឹតភាពរបស់ គ.ជ.ប និងការកែទម្រង់ការបោះឆ្នោតនៅកម្ពុជានាពេលខាងមុខ ដោយ គ.ជ.ប គួរធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជាអាណត្តិថ្មីនេះ។

**ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានពន្យល់ជូនប្រតិភូយ៉ាងលម្អិតផ្អែកលើរដ្ឋធម្មនុញ្ញ និងមូលដ្ឋានច្បាប់ស្តីពីការបោះឆ្នោតជាធរមាន ដែល គ.ជ.ប ត្រូវគោរព និងអនុវត្តក្នុងសមត្ថកិច្ចរបស់ខ្លួន ហើយឯកឧត្តមប្រធាន សង្ឃឹមថា នឹងមានជំនួបពិភាក្សាគ្នាជាបន្តទៀត។

ជំនួបពិភាក្សាការងាររវាងភាគីទាំងពីរបានប្រព្រឹត្តទៅអស់រយៈពេលជិត ២ (ពីរ) ម៉ោង ប្រកបដោយភាពយោគយល់គ្នា។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh